# ការប្រលងបញ្ចប់វគ្គ

## ? សំនួរទី ១:

តើធាតុសំខាន់ទាំង ៣ នៃដំណើរការធ្វើសេចក្តីសំរេចបែបលទ្ធិប្រជាធិបតេយ្យមានអ្វីខ្លះ?

ចូរឱ្យឧទាហរណ៍មួយ ចំពោះធាតុនីមួយៗ និង បញ្ជាក់ពីមាត្រាមួយនៃរដ្ឋធម្មនុញ្ញកម្ពុជាដែលពាក់ព័ន្ធនឹង ធាតុនីមួយៗនោះផង ។

## ? សំនួរទី ២:

តើអ្នកតាក់តែងច្បាប់ ត្រូវតែធ្វើការពិចារណានៅពេលដែលពួកគេចង់បញ្ញត្តិការដាក់កំហិតលើសិទ្ធិមួយ នៅក្នុងច្បាប់?

## ? សំនួរទី ៣:

មាត្រា៤៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលក្រុមប្រឹក្សាឃុំ សង្កាត់ មានខ្លឹមសារដូចតទៅនេះ:

"ក្នុងតួនាទីបំរើការងារមូលដ្ឋាន រដ្ឋបាលឃុំ សង្កាត់ មានភារកិច្ចៈ

- រៀបចំចាត់ចែងសេវាសាធារណៈចាំបាច់
- លើកទឹកចិត្តឱ្យមានផាសុកភាព និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ"

តើអ្វីទៅជាបញ្ហាដែលមាននៅក្នុងអត្ថបទមាត្រានេះ? ចូររៀបរាប់អំពីបញ្ហានោះ និងពន្យល់ថាតើហេតុអ្វីបានវាជាបញ្ហា!

## ? សំនួរទី ៤:

មាត្រា៤៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ មានខ្លឹមសារ ដូចតទៅ:

"តួនាទីមុខងារ និងអំណាចរបស់រដ្ឋបាលឃុំ សង្កាត់ អាចកំណត់លំអិតជាក់ស្តែងបន្ថែមទៀតដោយអនុក្រិត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។"

តើមាត្រានេះស្របនឹងរដ្ឋធម្មនុញ្ញដែរឬទេ? ចូរផ្តល់ហេតុផលសំរាប់ចំលើយរបស់អ្នក!

**? សំនួរទី ៥:**

តើសិទ្ធិរបស់អ្នកតាក់តែងច្បាប់ ក្នុងការបើកការពិភាក្សាជាសាធារណៈមួយនៅក្នុងរដ្ឋសភា ត្រូវបានការពារយ៉ាងដូចម្ដេចដែរ? សូមកុំភ្លេចបញ្ជាក់អំពីមាត្រានានាដែលពាក់ព័ន្ធ!

**? សំនួរទី ៦:**

តើរដ្ឋសភា និងព្រឹទ្ធសភា ខុសគ្នាត្រង់ណាខ្លះ?

**? សំនួរទី ៧:**

សកម្មភាពបញ្ចុះបញ្ចូល អាចសង្កត់ធ្ងន់លើ ៣ ផ្នែកខុសៗគ្នា:

- លើអ្នកតាក់តែងច្បាប់ផ្ទាល់
- លើដំណើរការតាក់តែងច្បាប់
- លើច្បាប់ដែលអនុម័តហើយ ។

ចូរផ្ដល់នូវឧទាហរណ៍ ២ នៃសកម្មភាពបញ្ចុះបញ្ចូលនៅក្នុងផ្នែកនីមួយៗ ។

**? សំនួរទី ៨:**

តើដំណាក់កាលសំខាន់ទាំង ៤ នៃដំណើរការតាក់តែងច្បាប់ រហូតដល់ច្បាប់ថ្មីមួយចូលជាធរមាននោះមានអ្វីខ្លះ?